ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម
មកដល់. ថ្ងៃទី.០៧...ខែ.មិថុនា ឆ្នាំ២០១៦
លេខ............១៣៨
ម៉ោង............ព្រឹក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤២១៤ កសក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៦

**សូមជម្រាបជូន**
**ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសិក្សា និងរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនៅក្នុងអនុវិស័យនៃវិស័យកសិកម្ម។

**យោង** ៖ ចំណារឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងជ្រាបថា ដើម្បីគាំទ្រ និងជំរុញនូវការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា ឲ្យមានប្រសិទ្ធភាព គ្រប់អង្គភាពទាំងអស់ដែលស្ថិតនៅក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសិក្សា និងរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអនុវិស័យរបស់ខ្លួនដូចជា៖ សេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ គោលនយោបាយជាតិ និងប្រកាស ឲ្យបានសមស្របទាន់ពេលវេលា តាមតម្រូវការជាក់ស្តែងនៃស្ថានភាពរីកចម្រើនក្នុងវិស័យកសិកម្មនាពេលបច្ចុប្បន្ន ដោយត្រូវផ្ញើមកក្រសួងជាការប្រញាប់ដើម្បីក្រសួងពិនិត្យ និងចាត់ចែងប្រជុំពិភាក្សាតាមនីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើឲ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

**អគ្គលេខាធិការ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចម្លងជូន៖**
-ថ្នាក់ដឹកនាំក្រសួង
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320